ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា  ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៧២ ត្រីមាសទី០៣ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៥-១២-២០២១ -ព្រះរាជក្រម នស/រកម/១២២១/០២០ ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ៨៨៧៥


### ២~ព្រះរាជក្រឹត្យ


១៤-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៣៩ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ហ៊ឹម សុនា** ជាអនុរដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ ៨៩៤២

១៤-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤០ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **នូ សម្បត្តិ** ពីទីប្រឹក្សារាជរដ្ឋាភិបាល និងតែងតាំង និងផ្តល់ឋានៈដល់ឯកឧត្តម **នៅ មូរ៉ា** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៨៩៤៣

១៤-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ជ័ង ហ៊ូចឹង** (ZHUANG HOUCHENG) ជនជាតិចិន សញ្ជាតិចិន ៨៩៤៤

១៤-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **វ៉ាង រិនចុង** (WANG, RENZHONG) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ឈិន សេងគង់** (CHEN SENGKONG) ៨៩៤៥

១៤-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ី អ៊ីនឆាវ** (XU, ENCHAO) ជនជាតិចិន សញ្ជាតិចិន ៨៩៤៦

១៥-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឃូ ថេវ៉ន់** (KOO TAE WON) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ ដោយប្តូរឈ្មោះជា **ឃូ ដារ៉ា** (KOO DARA) ៨៩៤៧

១៥-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៤៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **លូ ជេហ៊ី** (LUO JIHE) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **លូ ហោយ៉ាង**(LUO HAOYANG) ៨៩៤៨


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៤-១២-២០២១ -អនុក្រឹត្យលេខ ២៤២ អនក្រ.បក ស្តីពី ការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា ៨៩៤៩

១៤-១២-២០២១ -អនុក្រឹត្យលេខ ២៤៣ អនក្រ.បក ស្តីពី ការកំណត់ផ្ទៃបឹងមេទឹកបែកក្អម ស្ថិតនៅឃុំព្រែកអញ្ចាញ និងបឹងមេទឹកអំពៅខៀប ស្ថិតក្នុងឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ ៨៩៥៦

| | | |
|---|---|---|
| ១៤-១២-២០២១ | -អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី | ៨៩៦២ |
| ១៤-១២-២០២១ | -អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី | ៨៩៦៤ |
| ១៤-១២-២០២១ | -អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ | ៨៩៦៥ |
| ១៤-១២-២០២១ | -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ | ៨៩៦៦ |
| ១៥-១២-២០២១ | -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្ដិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ | ៨៩៦៧ |
| ១៦-១២-២០២១ | -អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្ដិ ជាកិច្ចបច្ឆាមរណៈ | ៨៩៦៩ |
| ១៦-១២-២០២១ | -អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្ដីពី ការបញ្ចប់មុខតំណែងមន្ត្រីរាជការ | ៨៩៧១ |
| ១៦-១២-២០២១ | -អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្ដិមន្ត្រីនគរបាលជាតិកម្ពុជា | ៨៩៧២ |


## ២~សេចក្ដីសម្រេច


| | | |
|---|---|---|
| ១៤-១២-២០២១ | -សេចក្ដីសម្រេចលេខ ១២១ សសរ ស្ដីពី ការបង្កើតការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជានៅតំបន់សេនដៃ ប្រទេសជប៉ុន | ៨៩៧៣ |


# III~ការងារបណ្ដាក្រសួង

## ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ៨-៧-២០២១ | -សេចក្ដីសម្រេចលេខ ០៣៦ សហវ ស្ដីពី ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៦ | ៨៩៧៥ |


## ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


| | | |
|---|---|---|
| ១០-៩-២០២១ | -ប្រកាសលេខ ៣១៩ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជេនេរ៉ល អេនធើប្រាយហ្គាម៉ិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរ និងចាក់សម្លៀកបំពាក់ | ៨៩៧៧ |
| ១០-៩-២០២១ | -ប្រកាសលេខ ៣២០ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូសិន អឺភែរឺល មេនូហ្វេកឆឺរីង ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៨៩៨០ |
| ១៣-៩-២០២១ | -ប្រកាសលេខ ៣២៤ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ីង លី (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងផលិតម៉ាស | ៨៩៨៣ |
| ១៣-៩-២០២១ | -ប្រកាសលេខ ៣២៥ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កាថាយ៉ា (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ វាយនភណ្ឌ | ៨៩៨៦ |


## ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


| | | |
|---|---|---|
| ៨-១២-២០២០ | -ប្រកាសលេខ ០៦៤០ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៦៤០ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២០ | ៨៩៨៩ |
| ៨-១២-២០២០ | -ប្រកាសលេខ ០៦៤១ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៦៤១ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២០ | ៨៩៩៣ |
| ៨-១២-២០២០ | -ប្រកាសលេខ ០៦៤២ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៦៤២ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២០ | ៨៩៩៧ |

# ព្រះរាជក្រម

## យើង

នស/រកម/១២២១/០២០

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់

# ស្ដីពី

# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ
# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី១
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ
## ផ្នែកទី១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១ .-**

ត្រូវបានយល់ព្រមលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ត១**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា២ .-**

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................៣០ ៣៩៥ ៨៥៥,០ លានរៀល
- អនុវត្តជាក់ស្តែង....................................... ២៨ ៥០០ ៣៧២,៥ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុចំនួន........................................១ ៨៩៥ ៤៨២,៥ លានរៀល។

**មាត្រា៣ .-**

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................៣១ ៨៣៥ ៥៦៣,៦ លានរៀល
- អនុវត្តជាក់ស្តែង....................................... ២៩ ៥០២ ៧៤៦,៥ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុចំនួន........................................២ ៣៣២ ៨១៧,០ លានរៀល។

**មាត្រា៤ .-**

ចំណូលថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងចំណុច I នៃតារាង "**ខ១**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ចំណាយថវិកាថ្នាក់ជាតិដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង "**គ១**" និងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានបង្ហាញលម្អិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមប្រភេទនៅក្នុងតារាង "**គ២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

លទ្ធផលដែលសម្រេចបានពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តមិនឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០៖ ចំពោះចំណូលថវិកាត្រូវបានបង្ហាញនៅក្នុងចំណុច II នៃតារាង "**ខ១**" និងចំពោះចំណាយថវិកាត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**គ៣**" ដូចមានភ្ជាប់ជាមួយច្បាប់នេះ។

## ផ្នែកទី២
## កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាអនុវត្តឆ្លងកាត់រតនាគារជាតិ

**មាត្រា៥.-**

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................២៤ ៣៤២ ៦៦៥,០ លានរៀល
- អនុវត្តជាក់ស្តែង........................................២៣ ៣១២ ៦២៨,៧ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុចំនួន........................................១ ០៣០ ០៣៦,៣ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត
- ច្បាប់ហិរញ្ញវត្ថុ........................................២៣ ៨៩៩ ៣២៤,០ លានរៀល
- អនុវត្តជាក់ស្តែង........................................២១ ៤២០ ៩៨៩,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន............................២ ៤៧៨ ៣៣៤,៩ លានរៀល។

២. ចំណូលមូលធន
- ច្បាប់ហិរញ្ញវត្ថុ........................................ ៤៤៣ ៣៤១,០ លានរៀល
- អនុវត្តជាក់ស្តែង........................................១ ៨៩១ ៦៣៩,៦ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន............................ ១ ៤៤៨ ២៩៨,៦ លានរៀល។

ក. ចំណូលមូលធនក្នុងប្រទេស
- ច្បាប់ហិរញ្ញវត្ថុ........................................១៩៣ ៣៤១,០ លានរៀល
- អនុវត្តជាក់ស្តែង........................................១៨៥ ២៤៣,៨ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន............................ ៨ ០៩៧,២ លានរៀល។

ខ. ចំណូលមូលធនក្រៅប្រទេស(មូលនិធិទ្រទ្រង់ថវិកា)
- ច្បាប់ហិរញ្ញវត្ថុ........................................២៥០ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែង........................................១ ៧០៦ ៣៩៥,៨ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន............................ ១ ៤៥៦ ៣៩៥,៨ លានរៀល។

**មាត្រា៦ .-**

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................២៥ ៧៨២ ៣៧៣,៦ លានរៀល
- អនុវត្តជាក់ស្តែង.........................................២៤ ៣១៥ ០០២,៧ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុចំនួន.........................................១ ៤៦៧ ៣៧០,៩ លានរៀល
ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយចរន្ត
- ច្បាប់ហិរញ្ញវត្ថុ..........................................១៧ ៩៥២ ៥៩២,៦ លានរៀល
- អនុវត្តជាក់ស្តែង.........................................១៧ ៣៤៥ ៣៤៤,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន...............................៦០៧ ២៤៨,៥ លានរៀល។

២. ចំណាយមូលធន
- ច្បាប់ហិរញ្ញវត្ថុ.......................................... ៧ ៨២៩ ៧៨១,០ លានរៀល
- អនុវត្តជាក់ស្តែង...........................................៦ ៩៦៩ ៦៥៨,៦ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន...............................៨៦០ ១២២,៤ លានរៀល។

ក. ចំណាយមូលធនសម្រាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស
- ច្បាប់ហិរញ្ញវត្ថុ....................................... ៦ ៧២៣ ៨៥៩,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................៥ ៨៨៧ ៤១៩,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..........................៨៣៦ ៤៣៩,៣ លានរៀល។

ខ. ចំណាយមូលធនសម្រាប់ការទូទាត់ការខ្ចី
- ច្បាប់ហិរញ្ញវត្ថុ.......................................១ ១០៥ ៩២២,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................១ ០៨២ ២៣៨,៩ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន........................... ២៣ ៦៨៣,១ លានរៀល។

**មាត្រា៧ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាជាក់ស្តែងឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង...........................២៣ ៣១២ ៦២៨,៧ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.......................... ២៤ ៣១៥ ០០២,៧ លានរៀល
- ឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំមានចំនួន...... (-) ១ ០០២ ៣៧៤,០ លានរៀល។

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៅក្នុងមាត្រា៧៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ មានចំនួនទឹកប្រាក់(-)១ ០០២ ៣៧៤,០ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផលរបស់រតនាគារជាតិ។

# ផ្នែកទី៣
# បទប្បញ្ញត្តិស្តីពី
# និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម

**មាត្រា៨ .-**

ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងយោងមាត្រា១២នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងយោងតាមតម្រូវការចាំបាច់ជាក់ស្តែងរបស់រាជរដ្ឋាភិបាល ត្រូវបានអនុម័តយល់ព្រមលើកិច្ចប្រតិបត្តិការចំណាយឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដូចខាងក្រោមៈ

១-ផ្តល់ឥណទានថវិកាបន្ថែមៈ

- ឥណទានថវិកាបន្ថែម.................................១ ២៧៥ ៦០០,០ លានរៀល
- អនុវត្តជាក់ស្តែង...........................................១ ២៥៩ ៣៨០,០ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែមចំនួន.........................១៦ ២២០,០ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅៈ

ក. ផ្តល់ជូនធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្មៈ

- ឥណទានថវិកាបន្ថែម......................................៣២៨ ៦០០,០ លានរៀល
- អនុវត្តជាក់ស្តែង...........................................៣២៧ ៤០០,០ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែមចំនួន.........................១ ២០០,០ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅៈ

ក.១. សម្រាប់គាំទ្រដល់សិប្បកម្ម សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកែច្នៃផលិតផលកសិកម្ម វិស័យកសិ-ឧស្សាហកម្ម និងវិស័យកសិកម្មៈ

- ឥណទានថវិកាបន្ថែម......................................២០៥ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែង...........................................២០៥ ០០០,០ លានរៀល។

ក.២. សម្រាប់ផ្តល់ឥណទានដល់រោងម៉ាស៊ីនកិនស្រូវដើម្បីប្រមូលទិញស្រូវពីប្រជាកសិករក្នុងរដូវប្រមូលផលធំចុងឆ្នាំ២០២០ៈ

- ឥណទានថវិកាបន្ថែម.................................១២៣ ៦០០,០ លានរៀល
- អនុវត្តជាក់ស្តែង......................................១២២ ៤០០,០ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែមចំនួន.....................១ ២០០,០ លានរៀល។

ខ.ផ្តល់ជូនក្រសួងសុខាភិបាលសម្រាប់ឧបត្ថម្ភធនដល់មន្ទីរពេទ្យកាល់ម៉ែត ដើម្បីអនុវត្តការងារសាងសង់អគារមជ្ឈមណ្ឌលពហុឯកទេសៈ

- ឥណទានថវិកាបន្ថែម.................................១២៣ ០០០,០លានរៀល
- អនុវត្តជាក់ស្តែង.........................................១២១ ៩៨០,០ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែមចំនួន.......................១ ០២០,០ លានរៀល។

គ.ផ្តល់ទុនដល់សាជីវកម្មធានាឥណទានកម្ពុជា៖

- ឥណទានថវិកាបន្ថែម......................................៨២៤ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែង..............................................៨១០ ០០០,០ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែមចំនួន..........................១៤ ០០០,០ លានរៀល។

២.ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលឃុំ សង្កាត់៖

- ឥណទានថវិកាបន្ថែម......................................១៤០ ០៦៩,២ លានរៀល
- អនុវត្តជាក់ស្តែង..............................................១៤០ ០៦៩,២ លានរៀល។

៣.រាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេបន្ថែម៖

- អនុញ្ញាតឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេបន្ថែម........... ៥០០,០ លានអេសដេអ៊ែរ
- អនុវត្តជាក់ស្តែងខ្ចីប្រាក់ពីគេបន្ថែមចំនួន..................... ០,០ លានអេសដេអ៊ែរ។

## ផ្នែកទី៤

## កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាអនុវត្តមិនឆ្លងកាត់ធនាគារជាតិ

**មាត្រា៩ .-**

ការអនុវត្តចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសអនុវត្តមិនឆ្លងកាត់ធនាគារជាតិ ដែលបានគ្រោងទុកចំណូលសរុបស្មើនឹងចំណាយសរុបសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ..............................................៦ ០៥៣ ១៩០,០ លានរៀល
- អនុវត្តជាក់ស្តែង..............................................៥ ១៨៧ ៧៤៣,៨ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.................................៨៦៥ ៤៤៦,២ លានរៀល។

## ផ្នែកទី៥

## តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

**មាត្រា១០ .-**

តុល្យភាពនៃថវិកាថ្នាក់ជាតិ ដែលបានសម្រេចជាស្ថាពរសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលក្នុងប្រទេសអនុវត្តជាក់ស្តែង..................២១ ៦០៦ ២៣២,៩ លានរៀល
  ក្នុងនោះចំណូលចរន្តអនុវត្តជាក់ស្តែង..................២១ ៤២០ ៩៨៩,១ លានរៀល
- ចំណាយថវិកា( មិនគិតការទូទាត់ការខ្ចី )
  អនុវត្តជាក់ស្តែង.............................................. ២៨ ៤២០ ៥០៧,៦ លានរៀល
  ក្នុងនោះចំណាយចរន្តអនុវត្តជាក់ស្តែង...............១៧ ៣៤៥ ៣៤៤,១ លានរៀល
- អតិរេកនៃថវិកាចរន្ត .................................. (+)៤ ០៧៥ ៦៤៥,០ លានរៀល

- ឱនភាពសរុបនៃថវិកាថ្នាក់ជាតិមានចំនួន.........(-)៦ ៨១៤ ២៧៤,៧ លានរៀល
- ហិរញ្ញប្បទាននៃឱនភាពមានចំនួន.................(+)៦ ៨១៤ ២៧៤,៧ លានរៀល។

គុណ្យភាពនៃថវិកាថ្នាក់ជាតិ ដែលបានសម្រេចជាស្ថាពរនៃកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

## ជំពូកទី២
## កិច្ចប្រតិបត្តិការថវិកាថ្នាក់ក្រោមជាតិ
## ផ្នែកទី១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១១ .-**

ត្រូវបានយល់ព្រមលើការអនុវត្តជំពូកទី៥ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។

លទ្ធផលដែលបានសម្រេចពីការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០៖ កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក៣**" កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក៤**" និងកិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក៥**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

## ផ្នែកទី២
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

**មាត្រា១២ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................២ ២៨៦ ៥៩១,០ លានរៀល
- អនុវត្តជាក់ស្តែង........................................២ ២១១ ១៤៦,៦ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត អនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុចំនួន........................................៧៥ ៤៤៤,៤ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត
- ច្បាប់ហិរញ្ញវត្ថុ........................................២ ២៣១ ៦៦៧,០ លានរៀល
- អនុវត្តជាក់ស្តែង........................................២ ១៥៦ ០៧៩,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន........................................៧៥ ៥៨៧,៧ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

- ច្បាប់ហិរញ្ញវត្ថុ.......................................................៥៤ ៩២៤,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................................៥៥ ០៦៧,៣ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................................១៤៣,៣ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងតារាង "**ខ២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៣ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................................២ ២៨៦ ៥៨៥,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................................១ ៩៤២ ៤៨៧,៥ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុចំនួន.......................................................៣៤៤ ០៩៧,៥ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយចរន្ត

- ច្បាប់ហិរញ្ញវត្ថុ.......................................................១ ៧៩២ ២២៩,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................................១ ៤៩៧ ៤៦២,៤ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................................២៩៤ ៧៦៦,៦ លានរៀល។

២. ចំណាយមូលធន

- ច្បាប់ហិរញ្ញវត្ថុ.......................................................៤៩៤ ៣៥៦,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................................៤៤៥ ០២៥,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................................៤៩ ៣៣០,៩ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតតាមជំពូកនៅក្នុងចំណុច ១ នៃតារាង "**គ៤**" និងត្រូវបានលម្អិតតាមរដ្ឋបាលរាជធានី ខេត្ត និងតាមជំពូកនៅក្នុងតារាង "**គ៥**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៤ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង.......................................២ ២១១ ១៤៦,៦ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.......................................១ ៩៤២ ៤៨៧,៥ លានរៀល
- អតិរេកនៃថវិកាមានចំនួន.......................................(+)២៦៨ ៦៥៩,១ លានរៀល។

អនុលោមតាមមាត្រា៤២ថ្មី នៃច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ អតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដែលមានទឹកប្រាក់ចំនួន(+)២៦៨ ៦៥៩,១ លានរៀល ត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិ ដើម្បីយោងបន្តទៅឆ្នាំថវិកាខាងមុខ។

## ផ្នែកទី៣
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា១៥ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចមានចែងក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ..........................................................២៧៤ ៣៩០,៧ លានរៀល
- អនុវត្តជាក់ស្ដែង.............................................. ២៧២ ៩៦៣,៤ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុចំនួន...................................................១ ៤២៧,៣ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ..........................................................៣១ ៦៤៦,០ លានរៀល
- អនុវត្តជាក់ស្ដែង.............................................. ៣០ ៤០៣,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.....................................១ ២៤២,៣ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

- ច្បាប់ហិរញ្ញវត្ថុ..........................................................២៤២ ៧៤៤,៧ លានរៀល
- អនុវត្តជាក់ស្ដែង..............................................២៤២ ៥៥៩,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.....................................១៨៥,០ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងតារាង "**២៣**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៦ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចមានចែងក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ..........................................................២៧៤ ៣៩០,៨ លានរៀល
- អនុវត្តជាក់ស្ដែង..............................................២៦៣ ៥០៤,៩ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុចំនួន............................................១០ ៨៨៥,៨ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតតាមជំពូកនៅក្នុងចំណុច ២ នៃតារាង "**គ៤**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៧ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង.............................២៧២ ៩៦៣,៤ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង............................ ២៦៣ ៥០៤,៩ លានរៀល
- អតិរេកនៃថវិកាមានចំនួន.................................(+)៩ ៤៥៨,៥ លានរៀល។

អនុលោមតាមមាត្រា៤២ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ អតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុក ដែលមានទឹកប្រាក់ចំនួន+៩ ៤៥៨,៥លានរៀល ត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅធនាគារជាតិដើម្បីយោងបន្តទៅឆ្នាំថវិកាខាងមុខ។

## ផ្នែកទី៤
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

**មាត្រា១៨ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ................................................៩៤៣ ៧៨១,២ លានរៀល
- អនុវត្តជាក់ស្តែង.............................................. ៨៤៦ ២៣០,៣ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុចំនួន............................................៩៧ ៥៥០,៩ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលមិនមែនសារពើពន្ធ

- ច្បាប់ហិរញ្ញវត្ថុ.......................................................... ០,០ លានរៀល
- អនុវត្តជាក់ស្តែង.........................................៤៩ ៧៩៣,១ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.................................៤៩ ៧៩៣,១ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

- ច្បាប់ហិរញ្ញវត្ថុ..........................................................៨០៣ ៧១២,០ លានរៀល
- អនុវត្តជាក់ស្តែង..........................................................៦៥៦ ៣៦៨,០ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន....................................១៤៧ ៣៤៤,០ លានរៀល។

៣. អតិរេកឆ្នាំ២០១៩ មានចំនួន....................................១៤០ ០៦៩,២ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតតាមមាតិកានៅក្នុងតារាង "ខ៤" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៩ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ..........................................................៩៤៣ ៧៨១,២ លានរៀល
- អនុវត្តជាក់ស្តែង..........................................................៦៥១ ៧៣០,៦ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុចំនួន..........................................................២៩២ ០៥០,៦ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយសង្កាត់ចំណុះរាជធានី

- ច្បាប់ហិរញ្ញវត្ថុ..........................................................៥៨ ៥៣៩,៩ លានរៀល
- អនុវត្តជាក់ស្តែង..........................................................៤៨ ៨៧៤,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន....................................៩ ៦៦៥,៨ លានរៀល។

២. ចំណាយសង្កាត់ចំណុះក្រុង

- ច្បាប់ហិរញ្ញវត្ថុ..........................................................៧៩ ៨៤៩,៧ លានរៀល
- អនុវត្តជាក់ស្តែង..........................................................៥២ ៧៣០,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន....................................២៧ ១១៩,៦ លានរៀល។

៣. ចំណាយឃុំ

- ច្បាប់ហិរញ្ញវត្ថុ..........................................................៨០៥ ៣៩១,៦ លានរៀល
- អនុវត្តជាក់ស្តែង..........................................................៥៥០ ១២៦,៤ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន....................................២៥៥ ២៦៥,២លានរៀល។

ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានបង្ហាញលម្អិតតាមមាតិកានៅក្នុងចំណុច ៣ នៃតារាង "ឥ៤" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា២០ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង................................៨៤៦ ២៣០,៣ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.............................. ៦៥១ ៧៣០,៦ លានរៀល
- អតិរេកនៃថវិកាមានចំនួន................................(+)១៩៤ ៤៩៩,៧ លានរៀល។

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ និងអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ អតិរេកថវិការដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២០ ដែលមានទឹកប្រាក់ចំនួន+១៩៤ ៤៩៩,៧លានរៀល ត្រូវយោងបន្តទៅឆ្នាំ២០២១។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ពុធ ១១កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០២១

នស.រកម.១២២១.០១៥

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

១៧/១៣

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក១"

## កិច្ចប្រតិបត្តិការទូទៅថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ | ឆ្នាំ២០២០ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល = ( I.១ + II.១ ) | 30 395 855,0 | 28 500 372,5 | 93,8% | -1 895 482,5 |
| សរុបចំណាយ = ( I.២ + II.២ ) | 31 833 998,1* | 29 502 746,5 | 92,7% | -2 331 251,7 |
| ឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំ | | -1 002 374,0 | | |
| I. កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ ដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិ | | | | |
| I.១.ចំណូលថវិកា | 24 342 665,0 | 23 312 628,7 | 95,8% | -1 030 036,3 |
| · ចំណូលចរន្ត | 23 899 324,0 | 21 420 989,1 | 89,6% | -2 478 334,9 |
| · ចំណូលមូលធន | 443 341,0 | 1 891 639,6 | 426,7% | +1 448 298,6 |
| + ចំណូលមូលធនក្នុងប្រទេស | 193 341,0 | 185 243,8 | 95,8% | -8 097,2 |
| + ចំណូលមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | 250 000,0 | 1 706 395,8 | 682,6% | +1 456 395,8 |
| I.២.ចំណាយថវិកា | 25 780 808,1 | 24 315 002,7 | 94,3% | -1 465 805,5 |
| · ចំណាយចរន្ត | 17 951 027,1* | 17 345 344,1 | 96,6% | -605 683,0 |
| · ចំណាយមូលធន | 7 829 781,0 | 6 969 658,6 | 89,0% | -860 122,4 |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 6 723 859,0 | 5 887 419,7 | 87,6% | -836 439,3 |
| + ការទូទាត់ការខ្ចី | 1 105 922,0 | 1 082 238,9 | 97,9% | -23 683,1 |
| II. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | | | |
| II.១.ចំណូលមូលធនសម្រាប់គម្រោង ដោយហិរញ្ញប្បទានក្រៅប្រទេស | 6 053 190,0 | 5 187 743,8 | 85,7% | -865 446,2 |
| II.២.ចំណាយមូលធនសម្រាប់គម្រោង ដោយហិរញ្ញប្បទានក្រៅប្រទេស | 6 053 190,0 | 5 187 743,8 | 85,7% | -865 446,2 |

(*)តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាចំនួន១ ២៧៥ ៦០០,០លានរៀល ដោយយោងការធ្វើនិយ័តការូបនីយកម្មនៃកិច្ចប្រតិបត្តិការ ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។



# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក២"

## តុល្យភាពនៃថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ហិរញ្ញប្បទាន |
|---|---|---|
| I- ចំណូលក្នុងប្រទេសសរុប | 21.606.232,9 | |
| I.១. ចំណូលចរន្ត | 21.420.989,1 | |
| I.២. ចំណូលមូលធនក្នុងប្រទេស | 185.243,8 | |
| II- ចំណាយថវិកាសរុប | 28.420.507,6 | |
| II.១. ចំណាយចរន្ត | 17.345.344,1 | |
| II.២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី ចំនួន ១ ០៨២ ២៣៨,៩លានរៀល) | 11.075.163,5 | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 5.887.419,7 | |
| - ដោយថវិកាថ្នាក់ជាតិ | 5.640.076,9 | |
| • គម្រោងវិនិយោគផ្ទាល់ | 4.984.085,8 | |
| • បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស | 655.991,1 | |
| - ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ | 247.342,7 | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 5.187.743,8 | |
| ក. អតិរេកនៃថវិកាចរន្ត (I.១-II.១) | (+)4.075.645,0 | |
| ខ. ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II) | (-)6.814.274,7 | |
| III- ហិរញ្ញប្បទាននៃឱនភាព | | (+)6.814.274,7 |
| ១. ហិរញ្ញប្បទានពីក្រៅប្រទេស | | (+)5.811.900,7 |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ | | (+)1.706.395,8 |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | (+)5.187.743,8 |
| • ការទូទាត់ការខ្ចី | | (-)1.082.238,9 |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | (+)1.002.374,0 |
| • បញ្ញើរាជរដ្ឋាភិបាល | | (+)1.002.374,0 |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "គ៣"

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលរាជធានី ខេត្ត | ឆ្នាំ២០២០ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូលថវិកា | 2.286.591,0 | 2.211.146,6 | 96,7% | -75.444,4 |
| សរុបចំណាយថវិកា | 2.286.585,0 | 1.942.487,5 | 85,0% | -344.097,5 |
| អតិរេកថវិការវាងចំណូលនិងចំណាយ | | 268.659,1 | | |
| កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត | | | | |
| I. ចំណូលថវិកា | 2.286.591,0 | 2.211.146,6 | 96,7% | -75.444,4 |
| - ចំណូលចរន្ត | 2.231.667,0 | 2.156.079,3 | 96,6% | -75.587,7 |
| • ចំណូលសារពើពន្ធ | 2.086.308,0 | 1.942.789,6 | 93,1% | -143.518,4 |
| • ចំណូលមិនមែនសារពើពន្ធ | 145.359,0 | 213.289,7 | 146,7% | +67.930,7 |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 54.924,0* | 55.067,3** | 100,3% | +143,3 |
| II. ចំណាយថវិកា | 2.286.585,0*** | 1.942.487,5 | 85,0% | -344.097,5 |
| - ចំណាយចរន្ត | 1.792.229,0 | 1.497.462,4 | 83,6% | -294.766,6 |
| - ចំណាយមូលធន | 494.356,0 | 445.025,1 | 90,0% | -49.330,9 |

(*) តួលេខនេះបូកបញ្ចូលនូវ ឥណទានថវិកាចំនួន៧ ៩០០លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកាជូនសាលាខេត្តសៀមរាប (មូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ)

(**) តួលេខនេះរួមមាន៖ ចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិ ចំនួន៤៧ ១៦៧,៣លានរៀល និងចំណូលឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ ចំនួន ៧ ៩០០លានរៀល។ ចំពោះចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិ បានបូកបញ្ចូលនូវចំណូលថវិកាចំនួន ១៤៣,៣លានរៀល យោងការធ្វើនិយ័តកម្មឥណទានថវិការបស់រដ្ឋបាលក្រុង ស្រុកផ្តល់ជូនរដ្ឋបាលខណ្ឌសម្រាប់ការធ្វើសមាហរណកម្មរចនាសម្ព័ន្ធការិយាល័យជំនាញ១៩ វិស័យ ។

(***)តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាសរុបចំនួនៈ ៤៧៩ ១៣០លានរៀល ក្នុងនោះ៖ (១)-ឥណទានថវិកាចំនួន៤៧១ ២៣០លានរៀល ដោយយោងប្រកាសបន្ថែមឥណទានថវិកាសម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត និង(២)-ឥណទានថវិកាចំនួន៧ ៩០០ លានរៀល យោងការធ្វើនិយ័តកម្មឥណទានថវិកាជូនសាលាខេត្តសៀមរាប (មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ)។ ឥណទានថវិកានេះរួមមាន ចំណាយចរន្តចំនួន៤៤៧ ១៣០លានរៀល និងចំណាយមូលធន ចំនួន៣២ ០០០លានរៀល ។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក៤"

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលក្រុង ស្រុក | ឆ្នាំ២០២០ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល | 274.390,8 | 272.963,4 | 99,5% | -1.427,3 |
| សរុបចំណាយ | 274.390,8 | 263.504,9 | 96,0% | -10.885,8 |
| អតិរេកថវិការវាងចំណូល និងចំណាយ | | +9.458,5 | | |
| កិច្ចប្រតិបត្តិការនៃថវិការបស់រដ្ឋបាលក្រុង ស្រុក | | | | |
| I. ចំណូលថវិកា | 274.390,8 | 272.963,4 | 99,5% | -1.427,3 |
| - ចំណូលចរន្ត | 31.646,0 | 30.403,7 | 96,1% | -1.242,3 |
| · ចំណូលមិនមែនសារពើពន្ធ | 31.646,0* | 30.403,7 | 96,1% | -1.242,3 |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 242.744,8** | 242.559,7 | 99,9% | -185,0 |
| II. ចំណាយថវិកា | 274.390,8 | 263.504,9 | 96,0% | -10.885,8 |
| - ចំណាយចរន្ត | 274.390,8*** | 263.504,9 | 96,0% | -10.885,8 |

(*) តួលេខនេះ បូកបញ្ចូលចំនួន១១ ៥៣៥,០លានរៀល ពីប្រកពការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ៤% និងតួលេខថវិកាចំនួន៨ ០០០លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថាន។

(**) តួលេខនេះ បូកបញ្ចូលថវិកាប្រកាសបន្ថែមឥណទានថវិកាការិយាល័យជំនាញ១៩ វិស័យ ដែលសមាហរណកម្មចូលរចនាសម្ព័ន្ធក្រុង ស្រុក ចំនួន១ ១៦៨,៧លានរៀល និងបូកបន្ថែមថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន១៦ស្រុក ចំនួន៦ ៤៥៩,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍។

(***)តួលេខនេះ បានបូកបញ្ចូលនូវៈ (១)-ឥណទានចំនួន១១ ៥៣៥,០លានរៀល ដោយយោងប្រកាសបន្ថែមឥណទានថវិកាពីការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ៤% សម្រាប់ចំណាយអភិវឌ្ឍន៍ (២)-ប្រកាសបន្ថែមឥណទានថវិកាចំនួន ៨ ០០០,០លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថាន (៣)-ប្រកាសបន្ថែមឥណទានថវិកាពីមូលនិធិវិនិយោករដ្ឋបាលថ្នាក់ក្រោមជាតិចំនួន១៦ស្រុក ចំនួន៦ ៤៥៩,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍ និង(៤)-ប្រកាសបន្ថែមឥណទានថវិកាការិយាល័យជំនាញ១៩ ស័យ ដែលសមាហរណកម្មចូលរចនាសម្ព័ន្ធក្រុង ស្រុក ចំនួន១ ១៦៨,៧លានរៀល។



# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក៥"

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលឃុំ សង្កាត់ | ឆ្នាំ២០២០ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ (-) |
| សរុបចំណូល | 943 781,2 | 846 230,3 | 89,7% | -97 550,9 |
| សរុបចំណាយ | 943 781,2 | 651 730,6 | 69,1% | -292 050,6 |
| អតិរេកថវិការវាងចំណូលនិងចំណាយ | | +194 499,7 | | |
| កិច្ចប្រតិបត្តិការនៃថវិការបស់រដ្ឋបាលឃុំ សង្កាត់ | | | | |
| I. ចំណូលថវិកា | 943 781,2 | 846 230,3 | 89,7% | -97 550,9 |
| - ចំណូលមិនមែនសារពើពន្ធ | 0,0 | 49 793,1 | | +49 793,1 |
| · ចំណូលសង្កាត់ចំណុះរាជធានី | 0,0 | 179,8 | | +179,8 |
| · ចំណូលសង្កាត់ចំណុះក្រុង | 0,0 | 4 631,1 | | +4 631,1 |
| · ចំណូលឃុំ | 0,0 | 44 982,1 | | +44 982,1 |
| - ចំណូលឧបត្ថម្ភពីថវិកាជាតិសរុប | 803 712,0* | 656 368,0 | 81,7% | -147 344,0 |
| · ចំណូលសង្កាត់ចំណុះរាជធានី | 42 393,5 | 42 357,5 | 99,9% | -35,9 |
| · ចំណូលសង្កាត់ចំណុះក្រុង | 66 337,9 | 52 944,0 | 79,8% | -13 393,8 |
| · ចំណូលឃុំ | 694 980,7 | 561 066,4 | 80,7% | -133 914,2 |
| - អតិរេកឆ្នាំ២០១៩ | 140 069,2** | 140 069,2 | 100,0% | 0,0 |
| II. ចំណាយថវិកា | 943 781,2 | 651 730,6 | 69,1% | -292 050,6 |
| - ចំណាយសរុប | 943 781,2 | 651 730,6 | 69,1% | -292 050,6 |
| · ចំណាយសង្កាត់ចំណុះរាជធានី | 58 539,9 | 48 874,1 | 83,5% | -9 665,8 |
| · ចំណាយសង្កាត់ចំណុះក្រុង | 79 849,7 | 52 730,1 | 66,0% | -27 119,6 |
| · ចំណាយឃុំ | 805 391,6 | 550 126,4 | 68,3% | -255 265,2 |

(*) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន៣៩៥លានរៀល ដោយយោងការធ្វើនិយ័តកម្មថវិកាតាមប្រកាសលេខ១៤៣០សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្ទេរឥណទានថវិកា

(**) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន១៤០ ០៦៩,២លានរៀល ដោយយោងការធ្វើនិយ័តការូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ខ១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២០ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបរួមចំណូលថវិកា (I+II) | | | | 30.395.855.000.000 | 28.500.372.510.560 | 93,8% | -1.895.482.489.440 |
| សរុបចំណូលអនុវត្តឆ្លងកាត់រតនាគារជាតិ (ក+ខ) | | | | 24.342.665.000.000 | 23.312.628.710.394 | 95,8% | -1.030.036.289.606 |
| ក្នុងនោះ ចំណូលក្នុងប្រទេស | | | | 24.092.665.000.000 | 21.606.232.955.848 | 89,7% | -2.486.432.044.152 |
| ក. សរុបចំណូលចរន្ត (ក្រុមទី១) | | | | 23.899.324.000.000 | 21.420.989.135.684 | 89,6% | -2.478.334.864.316 |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 23.899.324.000.000 | 21.420.989.135.684 | 89,6% | -2.478.334.864.316 |
| | ប្រភេទទី១: ចំណូលសារពើពន្ធ | | | 21.091.145.000.000 | 19.329.506.010.116 | 91,6% | -1.761.638.989.884 |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 18.321.745.000.000 | 17.117.682.831.049 | 93,4% | -1.204.062.168.951 |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលចំណេញ ប្រាក់ចំណូល) | 5.080.000.000.000 | 5.779.410.112.027 | 113,8% | +699.410.112.027 |
| | | 70011 | ពន្ធលើប្រាក់ចំណូល(រូបវន្តបុគ្គល) | 210.000.000.000 | 120.007.321.185 | 57,1% | -89.992.678.815 |
| | | 70012 | ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) | 4.000.000.000.000 | 4.738.772.111.395 | 118,5% | +738.772.111.395 |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 870.000.000.000 | 920.630.679.447 | 105,8% | +50.630.679.447 |
| | 7002 | | ពន្ធប្រយោល | 7.372.800.000.000 | 6.531.398.896.377 | 88,6% | -841.401.103.623 |
| | | 70021 | អាករលើផលរបរ | 0 | 2.036.325 | | +2.036.325 |
| | | 70022 | អាករលើតម្លៃបន្ថែម | 3.045.000.000.000 | 2.690.863.160.958 | 88,4% | -354.136.839.042 |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 812.000.000.000 | 790.527.148.776 | 97,4% | -21.472.851.224 |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 3.166.000.000.000 | 2.687.356.550.318 | 84,9% | -478.643.449.682 |
| | | 70027 | អាករលើតម្លៃបន្ថែម របបនាំចូល (ដាបន្ទុករបស់រដ្ឋ) | 349.800.000.000 | 362.650.000.000 | 103,7% | +12.850.000.000 |
| | 7003 | | អាករពិសេស | 5.733.945.000.000 | 4.580.802.965.675 | 79,9% | -1.153.142.034.325 |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 1.100.000.000.000 | 790.319.279.108 | 71,8% | -309.680.720.892 |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 514.500.000.000 | 609.925.614.335 | 118,5% | +95.425.614.335 |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 4.034.445.000.000 | 3.009.937.610.326 | 74,6% | -1.024.507.389.674 |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 85.000.000.000 | 170.620.461.906 | 200,7% | +85.620.461.906 |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 135.000.000.000 | 226.070.856.970 | 167,5% | +91.070.856.970 |
| | | 70082 | ប្រាក់ទោសទណ្ឌសារពើពន្ធ | 135.000.000.000 | 226.070.856.970 | 167,5% | +91.070.856.970 |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2.769.400.000.000 | 2.211.823.179.067 | 79,9% | -557.576.820.933 |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 2.719.800.000.000 | 2.187.813.655.248 | 80,4% | -531.986.344.752 |
| | | 71001 | ពន្ធគយពីការនាំចូល | 1.970.400.000.000 | 1.455.726.932.559 | 73,9% | -514.673.067.441 |
| | | 71002 | កម្រៃពីការងារគយ | 72.000.000.000 | 27.015.480.103 | 37,5% | -44.984.519.897 |
| | | 71003 | ពន្ធគយលើផលិតផលប្រេងសិលា | 310.000.000.000 | 307.065.418.954 | 99,1% | -2.934.581.046 |
| | | 71004 | អាករបន្ថែមលើផលិតផលប្រេងសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 342.000.000.000 | 373.325.482.097 | 109,2% | +31.325.482.097 |
| | | 71005 | ផលពីការលក់ទំនិញរឹបអូស និងទំនិញគ្មានការទាមទារ | 500.000.000 | 135.311.026 | 27,1% | -364.688.974 |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 12.000.000.000 | 13.545.030.509 | 112,9% | +1.545.030.509 |
| | | 71007 | ពន្ធនាំចូល (ដាបន្ទុករបស់រដ្ឋ) | 12.900.000.000 | 11.000.000.000 | 85,3% | -1.900.000.000 |
| | [illegible] | | ពន្ធនិងអាករលើការនាំចេញ | 49.600.000.000 | 24.009.523.819 | 48,4% | -25.590.476.181 |
| | | [illegible] | អាករលើការនាំចេញឈើ | 10.000.000.000 | 8.104.624.769 | 81,0% | -1.895.375.231 |
| | | [illegible] | អាករលើការនាំចេញកៅស៊ូ | 27.000.000.000 | 8.141.769.038 | 30,2% | -18.858.230.962 |
| | | [illegible] | អាករលើការនាំចេញទំនិញផ្សេងៗ | 12.100.000.000 | 7.560.589.745 | 62,5% | -4.539.410.255 |
| | | 71016 | ពន្ធផ្សេងៗពីការនាំចេញ | 500.000.000 | 202.540.267 | 40,5% | -297.459.733 |

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ខ១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២០ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| | ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | | | 2.808.179.000.000 | 2.091.483.125.568 | 74,5% | -716.695.874.432 |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 220.301.000.000 | 401.169.244.183 | 182,1% | +180.868.244.183 |
| | 7200 | | ផលសម្បទាន | 200.651.000.000 | 108.114.961.336 | 53,9% | -92.536.038.664 |
| | | 72001 | ផលពីនេសាទ | 2.650.000.000 | 861.924.500 | 32,5% | -1.788.075.500 |
| | | 72002 | ផលពីព្រៃឈើ | 17.775.000.000 | 10.958.296.259 | 61,7% | -6.816.703.741 |
| | | 72003 | សម្បទានប្រេងកាត | 93.101.000.000 | 8.617.765.076 | 9,3% | -84.483.234.924 |
| | | 72004 | សម្បទានរ៉ែ | 78.384.000.000 | 78.813.783.737 | 100,5% | +429.783.737 |
| | | 72005 | សម្បទានដីសេដ្ឋកិច្ច | 7.500.000.000 | 6.455.206.608 | 86,1% | -1.044.793.392 |
| | | 72008 | ផលសម្បទានផ្សេងៗ | 1.241.000.000 | 2.407.985.156 | 194,0% | +1.166.985.156 |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | 19.650.000.000 | 293.054.282.847 | 1.491,4% | +273.404.282.847 |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 19.650.000.000 | 293.054.282.847 | 1.491,4% | +273.404.282.847 |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 2.274.997.200.000 | 1.326.522.146.927 | 58,3% | -948.475.053.073 |
| | 7300 | | ផលទុនតាមវិស័យ | 962.660.500.000 | 417.093.633.656 | 43,3% | -545.566.866.344 |
| | | 73001 | ផលទុនអាកាសចរណ៍ស៊ីវិល | 261.371.000.000 | 134.525.327.052 | 51,5% | -126.845.672.948 |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 482.050.000.000 | 80.218.700.562 | 16,6% | -401.831.299.438 |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 44.049.200.000 | 8.039.518.941 | 18,3% | -36.009.681.059 |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 170.445.000.000 | 187.604.472.763 | 110,1% | +17.159.472.763 |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 939.600.000 | 636.617.000 | 67,8% | -302.983.000 |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 0 | 86.368.000 | | +86.368.000 |
| | | 73008 | ផលទុនផ្សេងៗទៀត | 3.805.700.000 | 5.982.629.338 | 157,2% | +2.176.929.338 |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 117.829.400.000 | 88.492.048.868 | 75,1% | -29.337.351.132 |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | 120.000.000 | 1.728.000 | 1,4% | -118.272.000 |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 117.427.400.000 | 87.996.009.668 | 74,9% | -29.431.390.332 |
| | | 73014 | ការលក់ផលិតផលកសិកម្ម | 262.000.000 | 220.449.600 | 84,1% | -41.550.400 |
| | | 73015 | ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬខូច | 20.000.000 | 195.463.300 | 977,3% | +175.463.300 |
| | | 73016 | ការលក់ឧបករណ៍អេឡិចត្រូនិចចាស់ៗ ឬខូច | 0 | 20.368.300 | | +20.368.300 |
| | | 73017 | ការលក់ឧបករណ៍អគ្គិសនីចាស់ៗ ឬខូច | 0 | 6.150.000 | | +6.150.000 |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | 0 | 51.880.000 | | +51.880.000 |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (១) | 70.909.100.000 | 89.745.694.173 | 126,6% | +18.836.594.173 |
| | | 73022 | [illegible] | 0 | 9.000.000 | | +9.000.000 |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 24.841.200.000 | 34.155.609.438 | 137,5% | +9.314.409.438 |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 2.094.900.000 | 683.078.000 | 32,6% | -1.411.822.000 |
| | | 73026 | ពិន័យ[illegible] | 4.479.400.000 | 4.553.686.945 | 101,7% | +74.286.945 |
| | | 73028 | ផលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាល ផ្សេងៗ | 39.493.600.000 | 50.344.319.790 | 127,5% | +10.850.719.790 |
| | 7303 | | ការផ្តល់សេវាកម្ម | 36.789.700.000 | 72.439.727.521 | 196,9% | +35.650.027.521 |
| | | [illegible] | [illegible]ម្រន[illegible]ទាំ | 12.151.800.000 | 10.458.222.286 | 86,1% | -1.693.577.714 |
| | | 73043 | [illegible] | 0 | 11.271.366.175 | | +11.271.366.175 |

# ការគ្រប់គ្រងឆ្នាំ២០២០
## តារាង "ខ១"
## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២០ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| | | 73044 | សេវាសំណង់ | 9.000.000.000 | 28.286.283.465 | 314,3% | +19.286.283.465 |
| | | 73045 | សេវាផ្តល់ព្រឹត្តិបត្រថ្កោលទោស | 2.709.600.000 | 2.460.198.000 | 90,8% | -249.402.000 |
| | | 73047 | សេវាលើពន្ធប្រថាប់ត្រា | 2.400.000.000 | 4.634.685.942 | 193,1% | +2.234.685.942 |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 10.528.300.000 | 15.328.971.653 | 145,6% | +4.800.671.653 |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | 258.770.500.000 | 240.171.720.828 | 92,8% | -18.598.779.172 |
| | | 73061 | ចំណូលពីកាតព្វកិច្ចកាស៊ីណូ | 198.089.000.000 | 163.750.864.407 | 82,7% | -34.338.135.593 |
| | | 73062 | ចំណូលពីកាតព្វកិច្ចឆ្នោត | 3.137.100.000 | 3.445.400.462 | 109,8% | +308.300.462 |
| | | 73065 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | 35.000.000 | 52.000.000 | 148,6% | +17.000.000 |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 36.509.400.000 | 49.700.402.236 | 136,1% | +13.191.002.236 |
| | | 73067 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 21.000.000.000 | 23.223.053.723 | 110,6% | +2.223.053.723 |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 35.217.000.000 | 25.643.060.283 | 72,8% | -9.573.939.717 |
| | | 73071 | ការជួលដីទំនេរ | 18.109.300.000 | 15.058.028.297 | 83,2% | -3.051.271.703 |
| | | 73072 | ការជួលដីមានអគារ | 16.776.300.000 | 10.325.843.186 | 61,6% | -6.450.456.814 |
| | | 73073 | ការជួលអគារ ឬសំណង់ផ្សេងៗ | 71.400.000 | 0 | 0.0% | -71.400.000 |
| | | 73074 | ការជួលសម្ភារ បរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ | 260.000.000 | 259.188.800 | 99,7% | -811.200 |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (២) | 792.821.000.000 | 392.936.261.598 | 49,6% | -399.884.738.402 |
| | | 73081 | ចំណូលពីការផ្តល់លិខិតឆ្លងដែន | 165.340.800.000 | 77.940.811.310 | 47,1% | -87.399.988.690 |
| | | 73082 | ចំណូលពីការផ្តល់ទិដ្ឋាការ | 580.791.200.000 | 232.766.360.111 | 40,1% | -348.024.839.889 |
| | | 73083 | ចំណូលពីការលក់លេខចុះបញ្ជីយានយន្ត | 6.000.000.000 | 15.417.027.303 | 257,0% | +9.417.027.303 |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងផលយាន | 650.000.000 | 5.214.869.552 | 802,3% | +4.564.869.552 |
| | | 73085 | ចំណូលពីការផ្តល់ប័ណ្ណបើកបរគ្រប់ប្រភេទ | 400.000.000 | 2.471.113.989 | 617,8% | +2.071.113.989 |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 4.324.000.000 | 13.962.542.484 | 322,9% | +9.638.542.484 |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | 35.315.000.000 | 45.163.536.849 | 127,9% | +9.848.536.849 |
| 74 | | | **ចំណូលពីការដាក់ពិន័យ និងការដាក់ទណ្ឌកម្ម** | **33.945.800.000** | **80.943.746.288** | **238,4%** | **+46.997.946.288** |
| | 7401 | | ផលពីការដាក់ពិន័យ និងការដាក់ទណ្ឌកម្ម | 21.945.800.000 | 77.521.569.850 | 353,2% | +55.575.769.850 |
| | | 74011 | ការពិន័យជាប្រាក់លើបទល្មើសចរាចរណ៍ផ្លូវគោក | 10.255.600.000 | 27.787.567.950 | 271,0% | +17.531.967.950 |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | 11.690.200.000 | 49.734.001.900 | 425,4% | +38.043.801.900 |
| | 7403 | | ចំណូលពីការរឹបអូស | 12.000.000.000 | 1.955.864.060 | 16,3% | -10.044.135.940 |
| | | 74032 | ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ | 12.000.000.000 | 1.955.864.060 | 16,3% | -10.044.135.940 |
| | 7408 | | ផលពីការពិន័យផ្សេងៗ | 0 | 1.466.312.378 | | +1.466.312.378 |
| | | 74081 | ផលពីការពិន័យផ្សេងៗ | 0 | 1.466.312.378 | | +1.466.312.378 |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | **132.000.000.000** | **92.190.279.386** | **69,8%** | **-39.809.720.614** |
| | 7504 | | មូលធនពីខាងក្រៅប្រទេស | 130.000.000.000 | 89.576.328.416 | 68,9% | -40.423.671.584 |
| | | 75042 | មូលធនពីក្រៅប្រទេសពហុភាគី | 130.000.000.000 | 89.576.328.416 | 68,9% | -40 423 671 584 |
| | 7508 | | ចំណូលពីមូលធនផ្សេងៗ | 2 000.000.000 | 2 613.950 970 | 130,7% | +613 950 970 |
| | | 75081 | ផលពី[illegible]ការពារបរិស្ថាន | 2.000.000.000 | 2.613.950.970 | 130,7% | +613 950 970 |
| 76 | | | **ផលហិរញ្ញវត្ថុ** | **146.926.000.000** | **139.951.246.824** | **95,3%** | **-6.974.753.176** |
| | 7601 | | ការប្រាក់នៃការវិនិយោគនិងការប្រាក់នៃប្រាក់បញ្ញើ | 146.926.000.000 | 109.082.853.731 | 74,2% | -37.843.146.269 |

# ការគ្រប់គ្រងឆ្នាំ២០២០
## តារាង "ខ១"
## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២០ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| | | 76011 | ការប្រាក់លើការឱ្យខ្ចី | 146.926.000.000 | 109.082.853.731 | 74,2% | -37.843.146.269 |
| | 7698 | | ផលហិរញ្ញវត្ថុផ្សេងទៀត | 0 | 30.868.393.093 | | +30.868.393.093 |
ក្នុងការអនុវត្តជាក់ស្តែង អាណាប័កដើមខ្សែ មានសិទ្ធិរក្សាទុកមុខចំណាយមួយចំនួនមិនប្រគល់សិទ្ធិជូនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ក្នុងករណីពិនិត្យឃើញថា មុខចំណាយទាំងនោះ មានចរិតជាយុទ្ធសាស្ត្រ វេទយិតភាព និងចាំបាច់ក្នុងការអនុវត្តកិច្ចលទ្ធកម្មប្រមូលផ្តុំ ដើម្បីបង្កើនកម្រិតគុណភាពនៃការប្រកួតប្រជែង ធានាស្តង់ដាររួមនៃទំនិញ សំណង់ និងសេវា ចំណេញពេលវេលា ព្រមទាំងអាចកាត់បន្ថយសោហ៊ុយចំណាយ។

អាណាប័កដើមខ្សែ មានសិទ្ធិរក្សាទុកមុខសញ្ញាចំណូលមួយចំនួន ឬទាំងស្រុង មិនប្រគល់សិទ្ធិជូនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ក្នុងករណីពិនិត្យឃើញថា មុខសញ្ញាចំណូលទាំងនោះមានចរិតយុទ្ធសាស្ត្រនិង/ឬវេទយិតភាព ព្រមទាំងបម្រើផលប្រយោជន៍ជារួមដល់ក្រសួង ស្ថាប័ន ។

## ជំពូកទី ៣
## ការបង្កើនចំនួនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ

**មាត្រា៧ .-**

ក្រសួង ស្ថាប័ន ដែលជាអាណាប័កដើមខ្សែ ត្រូវពិនិត្យ និងវាយតម្លៃលើអង្គភាពនានាស្ថិតក្រោមឱវាទជារៀងរាល់ឆ្នាំ ដើម្បីប្រគល់សិទ្ធិអំណាចឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ។

**មាត្រា៨ .-**

អង្គភាពថវិកា នៃក្រសួង ស្ថាប័ន ដែលត្រូវប្រគល់សិទ្ធិជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ត្រូវបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យ ដូចខាងក្រោម÷

១-ជាអង្គភាពដែលបង្កើតឡើងដោយផ្អែកលើគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងស្ថិតក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ហើយត្រូវបានកំណត់មុខងារ និងភារកិច្ច ព្រមទាំងបន្ទាត់គណនេយ្យភាពច្បាស់លាស់ ។

២-ជាអង្គភាពដែលត្រូវសម្រេចសមិទ្ធកម្ម ឬលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ នៅក្នុងកម្រិតដែលអាចវាស់វែងបាន ។

៣-អង្គភាពជាអគ្គនាយកដ្ឋាន ឬអង្គភាពដែលមានថ្នាក់ស្មើឬកម្រិតប្រហាក់ប្រហែលអគ្គនាយកដ្ឋាន ហើយមាន រចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់និងមានទំហំការងារ ចំនួនបុគ្គលិក និងទំហំថវិកាសមស្រប ។ ចំពោះ អង្គភាពកម្រិតនាយកដ្ឋានដែលត្រូវបានផ្តល់សិទ្ធិរួចហើយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិន

ពេញលេញ គឺអាចរក្សាទុកតាមការអនុវត្តដូចពេលបច្ចុប្បន្នដដែល ក្នុងករណីដែលក្រសួង ស្ថាប័ន យល់ថាមានការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពការងារ និងសមិទ្ធកម្ម ។

៤- ជាអង្គភាពដែលមានភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងការដឹកនាំ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ គណនេយ្យភាព និងតម្លាភាព ។

៥- ជាអង្គភាពដែលមានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពការងារ ផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំ ព្រមទាំងការគ្រប់គ្រងការអនុវត្តផែនការសកម្មភាពការងារនិងថវិកា ប្រកបដោយប្រសិទ្ធភាព ។

៦- ជាអង្គភាពរដ្ឋដែលទទួលបានថវិកា តាមរយៈប្រព័ន្ធថវិកាជាតិ ។

៧- ជាអង្គភាពដែលទទួលបានការវិភាជថវិកាប្រចាំឆ្នាំ និងមានសមត្ថភាពទទួលខុសត្រូវលើការអនុវត្ត និងការតាមដានការអនុវត្តថវិកា ។

**មាត្រា៩ .-**

ក្រសួង ស្ថាប័ន ត្រូវជំរុញអង្គភាព ឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងត្រូវកំណត់ចំនួនឱ្យបានច្បាស់លាស់ ដើម្បីដាក់បញ្ចូលក្នុងផែនការសកម្មភាពជាក់លាក់ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ននីមួយៗ តាមឆ្នាំនីមួយៗដើម្បីអនុវត្ត ។

## ជំពូកទី ៤

## ការកំណត់ និងការបង្កើនចំនួនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ

**មាត្រា១០ .-**

អាណាប័កដើមខ្សែនៃក្រសួង ស្ថាប័ន ត្រូវពិនិត្យ និងវាយតម្លៃ លើសមត្ថភាព និងសមិទ្ធកម្មរបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ដែលស្ថិតក្រោមឱវាទ ជារៀងរាល់ឆ្នាំ ដើម្បីប្រគល់សិទ្ធិអំណាចឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ។

**មាត្រា១១ .-**

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ដែលត្រូវបានប្រគល់សិទ្ធិជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ត្រូវបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យ ដូចខាងក្រោម÷

១- ជាអង្គភាពដែលបំពេញបានតាមលក្ខខណ្ឌវិនិច្ឆ័យគ្រប់គ្រាន់ ជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ។

២- ជាអង្គភាពដែលមានរចនាសម្ព័ន្ធក្រោមឱវាទជានាយកដ្ឋាន ឬអង្គភាពដែលមានថ្នាក់ស្មើឬប្រហាក់ប្រហែលច្រើនជាង ៣ (បី) ហើយអង្គភាពក្រោមឱវាទទាំងនោះត្រូវសម្រេចសមិទ្ធកម្ម ឬលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ ក្នុងកម្រិតដែលអាចវាស់វែងបាន និងមានបុគ្គលិកបម្រើការងារក្នុងអង្គភាព

ចាប់ពី ១៥០ នាក់ ឡើងទៅ ។ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញដែលមានបុគ្គលិកបម្រើការងារក្រោម ១៥០ នាក់ អាចត្រូវបានអនុញ្ញាតប្រគល់សិទ្ធិជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ តាមរយៈការពិនិត្យ និងវាយតម្លៃរួមគ្នារវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី ។ ចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី ខេត្ត ដែលត្រូវបានផ្តល់សិទ្ធិជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញរួចទៅហើយនោះ ត្រូវរក្សាទុកតាមការអនុវត្តដូចពេលបច្ចុប្បន្នដដែល ។

៣-ជាអង្គភាពដែលមានសមត្ថភាពក្នុងការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាពេញលេញតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ហើយក៏អាចស្នើសុំការគាំទ្រ និងការសម្របសម្រួលពីអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុក្នុងករណីចាំបាច់ ។

៤-ជាអង្គភាពដែលត្រូវទទួលបានការវិភាជថវិកាជូនប្រចាំឆ្នាំ និងមានសមត្ថភាពទទួលខុសត្រូវពេញលេញលើការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តថវិកា និងការអនុវត្តសកម្មភាពការងាររបស់ខ្លួន ព្រមទាំងត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា (របាយការណ៍ចំណូល-ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្ម) ស្របតាមការណែនាំរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ/ក្រុមការងារថវិកា ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន និងផ្ញើជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន តាមកាលបរិច្ឆេទដែលបានកំណត់ ។

**មាត្រា១២ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី ត្រូវធ្វើកិច្ចសហប្រតិបត្តិការ និងកិច្ចសហការគ្នាដើម្បីកំណត់ និងជំរុញអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងត្រូវកំណត់ចំនួនឱ្យបានច្បាស់លាស់ ដើម្បីដាក់បញ្ចូលក្នុងផែនការសកម្មភាពជាក់លាក់ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ននីមួយៗ តាមឆ្នាំនីមួយៗដើម្បីអនុវត្ត ។

## ជំពូកទី ៥

## សិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា

**មាត្រា១៣ .-**

សិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា១៤ .-**

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ដែលត្រូវរៀបចំ និងបង្កើតដោយក្រសួង ស្ថាប័ន ត្រូវដាក់ឱ្យដំណើរការជាផ្លូវការ ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី ។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១០ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១២៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់ផ្ទៃបឹងមេទឹកបែកក្អម ស្ថិតនៅឃុំព្រែកអញ្ចាញ និងបឹងមេទឹកអំពៅខ្មៅ ស្ថិតក្នុងឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការ កំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កំណត់ផ្ទៃបឹងមេទឹកបែកក្អមទំហំ ៥៣ ហិកតា ៩៦ អា ៦៦ សង់ទីអា ស្ថិតនៅក្នុងឃុំព្រែកអញ្ចាញ និងបឹងមេទឹកអំពៅខ្មៅ ទំហំ ១២៨ ហិកតា ៤៤ អា ៩១ សង់ទីអា ស្ថិតនៅក្នុងឃុំសំបួរមាស ស្រុកមុខកំពូល

ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 រួមមាន ៤៣ ចំណុចសម្រាប់បឹងមេទឹកបែកក្អម និង ចំនួន ៦៥ ចំណុចសម្រាប់បឹងមេទឹកអំពៅខៀប ដូចខាងក្រោម៖

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 494977.349 | 1297454.532 | 23 | 493577.987 | 1297636.775 |
| 2 | 495068.026 | 1297401.383 | 24 | 493518.603 | 1297636.246 |
| 3 | 495150.414 | 1297350.935 | 25 | 493450.650 | 1297758.706 |
| 4 | 495233.535 | 1297294.692 | 26 | 493400.628 | 1297845.172 |
| 5 | 495177.981 | 1297156.430 | 27 | 493463.356 | 1297920.962 |
| 6 | 495054.420 | 1297222.699 | 28 | 493533.236 | 1297994.912 |
| 7 | 494994.410 | 1297129.919 | 29 | 493613.780 | 1298056.169 |
| 8 | 494912.590 | 1297173.102 | 30 | 493692.911 | 1298118.226 |
| 9 | 494826.576 | 1297219.051 | 31 | 493824.288 | 1298055.942 |
| 10 | 494738.363 | 1297265.941 | 32 | 493917.168 | 1298012.741 |
| 11 | 494659.250 | 1297309.944 | 33 | 494007.907 | 1297973.428 |
| 12 | 494583.133 | 1297350.516 | 34 | 494100.658 | 1297932.925 |
| 13 | 494503.701 | 1297393.310 | 35 | 494190.210 | 1297890.028 |
| 14 | 494395.369 | 1297448.978 | 36 | 494279.364 | 1297845.630 |
| 15 | 494258.008 | 1297523.272 | 37 | 494371.003 | 1297802.440 |
| 16 | 494119.326 | 1297599.472 | 38 | 494459.016 | 1297756.376 |
| 17 | 494039.172 | 1297641.739 | 39 | 494541.092 | 1297709.333 |
| 18 | 493951.888 | 1297695.112 | 40 | 494631.178 | 1297654.360 |
| 19 | 493864.386 | 1297746.926 | 41 | 494719.519 | 1297604.417 |
| 20 | 493775.851 | 1297800.459 | 42 | 494806.282 | 1297556.598 |
| 21 | 493663.619 | 1297773.358 | 43 | 494891.575 | 1297504.384 |
| 22 | 493576.750 | 1297723.195 | | | |

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 490410.424 | 1301123.721 | 34 | 490850.309 | 1299669.383 |
| 2 | 490373.123 | 1301030.285 | 35 | 490857.255 | 1299769.217 |
| 3 | 490343.314 | 1300934.679 | 36 | 490862.785 | 1299869.170 |
| 4 | 490324.862 | 1300823.364 | 37 | 490866.468 | 1299968.898 |
| 5 | 490313.023 | 1300737.247 | 38 | 490870.805 | 1300068.858 |
| 6 | 490306.137 | 1300634.344 | 39 | 490880.211 | 1300168.403 |
| 7 | 490315.266 | 1300537.361 | 40 | 490892.638 | 1300266.877 |
| 8 | 490338.314 | 1300438.649 | 41 | 490908.670 | 1300365.269 |
| 9 | 490353.044 | 1300344.670 | 42 | 490921.854 | 1300464.528 |
| 10 | 490368.088 | 1300243.077 | 43 | 490936.221 | 1300563.167 |
| 11 | 490381.975 | 1300143.901 | 44 | 490945.946 | 1300662.966 |
| 12 | 490392.300 | 1300044.879 | 45 | 490944.795 | 1300764.160 |
| 13 | 490412.683 | 1299945.557 | 46 | 490959.154 | 1300861.717 |
| 14 | 490439.049 | 1299850.152 | 47 | 490975.870 | 1300958.412 |
| 15 | 490454.980 | 1299748.360 | 48 | 490986.336 | 1301059.732 |
| 16 | 490476.505 | 1299653.915 | 49 | 491002.088 | 1301158.245 |
| 17 | 490503.402 | 1299558.065 | 50 | 491021.836 | 1301255.930 |
| 18 | 490520.030 | 1299459.774 | 51 | 491039.982 | 1301356.143 |
| 19 | 490536.782 | 1299361.093 | 52 | 491073.073 | 1301448.605 |
| 20 | 490554.778 | 1299262.698 | 53 | 491122.402 | 1301534.579 |
| 21 | 490576.315 | 1299165.024 | 54 | 491176.726 | 1301618.782 |
| 22 | 490595.672 | 1299067.457 | 55 | 491235.230 | 1301710.496 |

| | | | | | |
|---|---|---|---|---|---|
| 23 | 490613.639 | 1298969.103 | 56 | 491151.888 | 1301759.427 |
| 24 | 490614.833 | 1298858.646 | 57 | 491053.547 | 1301800.047 |
| 25 | 490713.650 | 1298862.188 | 58 | 490980.317 | 1301736.250 |
| 26 | 490817.034 | 1298870.704 | 59 | 490890.341 | 1301656.040 |
| 27 | 490821.412 | 1298970.440 | 60 | 490832.597 | 1301603.577 |
| 28 | 490823.415 | 1299070.360 | 61 | 490756.490 | 1301536.347 |
| 29 | 490826.078 | 1299170.467 | 62 | 490676.104 | 1301462.096 |
| 30 | 490827.929 | 1299270.777 | 63 | 490609.691 | 1301400.586 |
| 31 | 490830.548 | 1299370.432 | 64 | 490510.692 | 1301295.688 |
| 32 | 490836.334 | 1299470.157 | 65 | 490451.571 | 1301214.527 |
| 33 | 490843.279 | 1299569.896 | | | |

**មាត្រា២ ._**

ផែនទីបង្ហាញទីតាំងផ្ទៃបឹងមេទឹកបែកក្អម និងបឹងមេទឹកអំពៅខ្មៅ ជាឧបសម្ព័ន្ធទី១ និងទី២ នៃអនុក្រឹត្យនេះ។

**មាត្រា៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១០កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ២៧អនក្រ.បក ចុះថ្ងៃទី.១៤.....ខែ.......ឆ្នាំ២០២១




តារាងនិយាមកាចំណុចព្រំបឹងមេទឹកបែកក្អម

Projection, UTM, Zone 48N

Datum,WGS,1984

| ID | E | N |
|---|---|---|
| 1 | 494977.349 | 1297454.532 |
| 2 | 495068.026 | 1297401.383 |
| 3 | 495150.414 | 1297350.935 |
| 4 | 495233.535 | 1297294.692 |
| 5 | 495177.981 | 1297156.430 |
| 6 | 495054.420 | 1297222.699 |
| 7 | 494994.410 | 1297129.919 |
| 8 | 494912.590 | 1297173.102 |
| 9 | 494826.576 | 1297219.051 |
| 10 | 494738.363 | 1297265.941 |
| 11 | 494659.250 | 1297309.944 |
| 12 | 494583.133 | 1297350.516 |
| 13 | 494503.701 | 1297393.310 |
| 14 | 494395.369 | 1297448.978 |
| 15 | 494258.008 | 1297523.272 |
| 16 | 494119.326 | 1297599.472 |
| 17 | 494039.172 | 1297641.739 |
| 18 | 493951.888 | 1297695.112 |
| 19 | 493864.386 | 1297746.926 |
| 20 | 493775.851 | 1297800.459 |
| 21 | 493663.619 | 1297773.358 |
| 22 | 493576.750 | 1297723.195 |
| 23 | 493577.987 | 1297636.775 |
| 24 | 493518.603 | 1297636.246 |
| 25 | 493450.650 | 1297758.706 |
| 26 | 493400.628 | 1297845.172 |
| 27 | 493463.356 | 1297920.962 |
| 28 | 493533.236 | 1297994.912 |
| 29 | 493613.780 | 1298056.169 |
| 30 | 493692.911 | 1298118.226 |
| 31 | 493824.288 | 1298055.942 |
| 32 | 493917.168 | 1298012.741 |
| 33 | 494007.907 | 1297973.428 |
| 34 | 494100.658 | 1297932.925 |
| 35 | 494190.210 | 1297890.028 |
| 36 | 494279.364 | 1297845.630 |
| 37 | 494371.003 | 1297802.440 |
| 38 | 494459.016 | 1297756.376 |
| 39 | 494541.092 | 1297709.333 |
| 40 | 494631.178 | 1297654.360 |
| 41 | 494719.519 | 1297604.417 |
| 42 | 494806.282 | 1297556.598 |
| 43 | 494891.575 | 1297504.384 |

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ២០២១




តារាងនិយាមការចំណុចព្រំបឹងមេទឹកអំពៅខ្មៅ

Projection UTM Zone 48N, Datum,WGS,1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 490410.424 | 1301123.721 | 34 | 490850.309 | 1299669.383 |
| 2 | 490373.123 | 1301030.285 | 35 | 490857.255 | 1299769.217 |
| 3 | 490343.314 | 1300934.679 | 36 | 490862.785 | 1299869.170 |
| 4 | 490324.862 | 1300823.364 | 37 | 490866.468 | 1299968.898 |
| 5 | 490313.023 | 1300737.247 | 38 | 490870.805 | 1300068.858 |
| 6 | 490306.137 | 1300634.344 | 39 | 490880.211 | 1300168.403 |
| 7 | 490315.266 | 1300537.361 | 40 | 490892.638 | 1300266.877 |
| 8 | 490338.314 | 1300438.649 | 41 | 490908.670 | 1300365.269 |
| 9 | 490353.044 | 1300344.670 | 42 | 490921.854 | 1300464.528 |
| 10 | 490368.088 | 1300243.077 | 43 | 490936.221 | 1300563.167 |
| 11 | 490381.975 | 1300143.901 | 44 | 490945.946 | 1300662.966 |
| 12 | 490392.300 | 1300044.879 | 45 | 490944.795 | 1300764.160 |
| 13 | 490412.683 | 1299945.557 | 46 | 490959.154 | 1300861.717 |
| 14 | 490439.049 | 1299850.152 | 47 | 490975.870 | 1300958.412 |
| 15 | 490454.980 | 1299748.360 | 48 | 490986.336 | 1301059.732 |
| 16 | 490476.505 | 1299653.915 | 49 | 491002.088 | 1301158.245 |
| 17 | 490503.402 | 1299558.065 | 50 | 491021.836 | 1301255.930 |
| 18 | 490520.030 | 1299459.774 | 51 | 491039.982 | 1301356.143 |
| 19 | 490536.782 | 1299361.093 | 52 | 491073.073 | 1301448.605 |
| 20 | 490554.778 | 1299262.698 | 53 | 491122.402 | 1301534.579 |
| 21 | 490576.315 | 1299165.024 | 54 | 491176.726 | 1301618.782 |
| 22 | 490595.672 | 1299067.457 | 55 | 491235.230 | 1301710.496 |
| 23 | 490613.639 | 1298969.103 | 56 | 491151.888 | 1301759.427 |
| 24 | 490614.833 | 1298858.646 | 57 | 491053.547 | 1301800.047 |
| 25 | 490713.650 | 1298862.188 | 58 | 490980.317 | 1301736.250 |
| 26 | 490817.034 | 1298870.704 | 59 | 490890.341 | 1301656.040 |
| 27 | 490821.412 | 1298970.440 | 60 | 490832.597 | 1301603.577 |
| 28 | 490823.415 | 1299070.360 | 61 | 490756.490 | 1301536.347 |
| 29 | 490826.078 | 1299170.467 | 62 | 490676.104 | 1301462.096 |
| 30 | 490827.929 | 1299270.777 | 63 | 490609.691 | 1301400.586 |
| 31 | 490830.548 | 1299370.432 | 64 | 490510.692 | 1301295.688 |
| 32 | 490836.334 | 1299470.157 | 65 | 490451.571 | 1301214.527 |
| 33 | 490843.279 | 1299569.896 | | | |

## ផែនទីបង្ហាញទីតាំងបឹងមេទឹកអំពៅខ្សៀប ស្ថិតនៅឃុំសំបូរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល




តារាងនិយាមកាចំណុចព្រំបឹងមេទឹកអំពៅខ្សៀប

Projection UTM Zone 48N, Datum,WGS,1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 490410.424 | 1301123.721 | 34 | 490850.309 | 1299669.383 |
| 2 | 490373.123 | 1301030.285 | 35 | 490857.255 | 1299769.217 |
| 3 | 490343.314 | 1300934.679 | 36 | 490862.785 | 1299869.170 |
| 4 | 490324.862 | 1300823.364 | 37 | 490866.468 | 1299968.898 |
| 5 | 490313.023 | 1300737.247 | 38 | 490870.805 | 1300068.858 |
| 6 | 490306.137 | 1300634.344 | 39 | 490880.211 | 1300168.403 |
| 7 | 490315.266 | 1300537.361 | 40 | 490892.638 | 1300266.877 |
| 8 | 490338.314 | 1300438.649 | 41 | 490908.670 | 1300365.269 |
| 9 | 490353.044 | 1300344.670 | 42 | 490921.854 | 1300464.528 |
| 10 | 490368.088 | 1300243.077 | 43 | 490936.221 | 1300563.167 |
| 11 | 490381.975 | 1300143.901 | 44 | 490945.946 | 1300662.966 |
| 12 | 490392.300 | 1300044.879 | 45 | 490944.795 | 1300764.160 |
| 13 | 490412.683 | 1299945.557 | 46 | 490959.154 | 1300861.717 |
| 14 | 490439.049 | 1299850.152 | 47 | 490975.870 | 1300958.412 |
| 15 | 490454.980 | 1299748.360 | 48 | 490986.336 | 1301059.732 |
| 16 | 490476.505 | 1299653.915 | 49 | 491002.088 | 1301158.245 |
| 17 | 490503.402 | 1299558.065 | 50 | 491021.836 | 1301255.930 |
| 18 | 490520.030 | 1299459.774 | 51 | 491039.982 | 1301356.143 |
| 19 | 490536.782 | 1299361.093 | 52 | 491073.073 | 1301448.605 |
| 20 | 490554.778 | 1299262.698 | 53 | 491122.402 | 1301534.579 |
| 21 | 490576.315 | 1299165.024 | 54 | 491176.726 | 1301618.782 |
| 22 | 490595.672 | 1299067.457 | 55 | 491235.230 | 1301710.496 |
| 23 | 490613.639 | 1298969.103 | 56 | 491151.888 | 1301759.427 |
| 24 | 490614.833 | 1298858.646 | 57 | 491053.547 | 1301800.047 |
| 25 | 490713.650 | 1298862.188 | 58 | 490980.317 | 1301736.250 |
| 26 | 490817.034 | 1298870.704 | 59 | 490890.341 | 1301656.040 |
| 27 | 490821.412 | 1298970.440 | 60 | 490832.597 | 1301603.577 |
| 28 | 490823.415 | 1299070.360 | 61 | 490756.490 | 1301536.347 |
| 29 | 490826.078 | 1299170.467 | 62 | 490676.104 | 1301462.096 |
| 30 | 490827.929 | 1299270.777 | 63 | 490609.691 | 1301400.586 |
| 31 | 490830.548 | 1299370.432 | 64 | 490510.692 | 1301295.688 |
| 32 | 490836.334 | 1299470.157 | 65 | 490451.571 | 1301214.527 |
| 33 | 490843.279 | 1299569.896 | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៦៩ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយសហមេត្រី**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១.** -បំពាក់មេដាយ**សហមេត្រី** តាមលំដាប់ថ្នាក់ ជូននាយនគរបាលអនុព័ន្ធស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន និងអនុព័ន្ធស្ថានទូតព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចំនួន ២រូប ដែលមានស្នាដៃល្អកិច្ចសហប្រតិបត្តិការរវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**សហមេត្រី** ថ្នាក់ **សេនា**

លោក ZHANG PING នាយនគរបាលទំនាក់ទំនងកិច្ចការនគរបាលអមស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា

ខ-មេដាយ**សហមេត្រី** ថ្នាក់ **អស្សឫទ្ធិ**

វរសេនីយ៍ឯក Jaturapat Bhiromkaew អនុព័ន្ធនគរបាលភូមិន្ទថៃអមស្ថានទូតព្រះរាជាណាចក្រថៃ ប្រចាំកម្ពុជា

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។⁄

ថ្ងៃ សៅរ៍ ១០ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៥៧០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា១.** -បំពាក់មេដាយ**សហមេត្រី** ថ្នាក់**ធិបឌិន្ទ** ជូនលោក TAKIZAWA Seiroku អតីតកុងស៊ុលកិត្តិយសកម្ពុជាប្រចាំខេត្តហុកកៃដូនៃប្រទេសជប៉ុន ដែលមានស្នាដៃល្អក្នុងការបំពេញការងារជាកុងស៊ុលកិត្តិយសកម្ពុជា អស់រយៈពេល ១៣ឆ្នាំ (២០០៧-២០២០) កន្លងមក។

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**..៥៧១..អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និង កែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ៈ** តែងតាំងលោក **វ៉ន ឡុង** ជាអធិការ នៃអគ្គាធិការដ្ឋាន របស់ក្រសួងផែនការ ។

**មាត្រា ២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ អង្គារ ១០ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧១ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តែងតាំងលោក **ម៉ុន រស្មី** ជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច របស់ក្រសួងអប់រំ យុវជន និងកីឡា ជំនួសឯកឧត្តម **រស់ សាលីន** ដែលបានទទួលភារកិច្ចថ្មី។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០ កើត ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** [illegible] អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

តម្លើងឋានន្តរស័ក្តិ លោក **សំអុល តាំងប៊ុនណាត** អត្តលេខ ១៩២៧ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ២ មកជា ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១១ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**៥៧៤.អនក្រ.តត

# អនុក្រឹត្យ

**ស្តីពី**

## ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ចំពោះនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

**ក-ឋានន្តរស័ក្តិវរសេនីយ៍ឯក**

-វរសេនីយ៍ទោ **ឡាយ យឿន** អត្តលេខ ០៣៩៧១៣ នាយរង លេខាធិការដ្ឋាន

សាលាហ្វឹកហ្វឺនរថក្រោះ បញ្ជាការដ្ឋានរថក្រោះ អគ្គបញ្ជាការដ្ឋាន

**ខ-ឋាននន្តរស័ក្តិចរនាទីឯក**

-វរនាវីទោ **ឡៀង នាថ** អត្តលេខ ១៣៦៣៧៨ ជំនួយការ អាវុធគ្រាប់ គ្រឿងផ្ទុះ

ការិយាល័យភស្តុភារ បញ្ជាការដ្ឋានការពារកោះឆ្នេរ កងទ័ពជើងទឹក

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៧៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការបញ្ចប់មុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

**មាត្រា១ :** បញ្ចប់មុខតំណែងលោក **ថាន់ ណារ៉ុន** ពីជំនួយការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៣៧៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនវរសេនីយ៍ទោ **ចាន់ គ្រីស្នា** អត្តលេខ ៦៨២៤១ នាយនគរបាលជាន់ខ្ពស់ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែ ពិសាខ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២១ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជា នៅតំបន់សេនដៃ ប្រទេសជប៉ុន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្ម មាត្រា២ និងមាត្រា១៥ នៃច្បាប់ស្ដីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើតការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាមួយ នៅតំបន់សេនដៃ ប្រទេសជប៉ុន ហៅថា **ការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាសេនដៃ** ។ព្រំដែនមណ្ឌលការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាសេនដៃ ត្រូវកំណត់តាមព្រំដែនតំបន់សេនដៃ ប្រទេសជប៉ុន។

**ប្រការ២ ._**

ការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាសេនដៃមានសមាជិកជ្រើសតាំងចំនួន ១៤ (ដប់បួន) រូប ដែលជ្រើសតាំងតាមការបោះឆ្នោត។

ការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាសេនដៃមិនប្រើប្រាស់ថវិកាជាតិឡើយ។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ១០កើត ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ [illegible] ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-សភាពាណិជ្ជកម្មកម្ពុជា
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: [illegible]... ស.ហ.វ. ........

# សេចក្ដីសម្រេច

## ស្ដីពី

## ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៦

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/២៤១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្ដីសម្រេចលេខ ០៤៤ សហវ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីកាលបរិច្ឆេទនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្ដីសម្រេចលេខ ០៥៨ សហវ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ស្ដីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី២
- បានឃើញសេចក្ដីសម្រេចលេខ ០៦៦ សហវ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ស្ដីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៣
- បានឃើញសេចក្ដីសម្រេចលេខ ០៨១ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៤

- បានឃើញសេចក្តីសម្រេចលេខ ០១២ សហវ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់ជុំទី៥
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

**ប្រការ១.-**

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបន្តអនុវត្ត សម្រាប់ជុំទី៦ ដែលមានរយៈពេល ០៣ (បី) ខែ គឺសម្រាប់ខែកក្កដា ខែសីហា និងខែកញ្ញា ឆ្នាំ២០២១។

រយៈពេលអនុវត្តបន្ត នឹងត្រូវកំណត់ដោយឡែក ផ្អែកតាមសភាពការណ៍វិវត្តន៍ជាក់ស្តែង។

**ប្រការ២.-**

ការបើកផ្តល់ប្រាក់ឧបត្ថម្ភ ត្រូវធ្វើឡើង ក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ។

**ប្រការ៣.-**

អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ.......... ខែ.......... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ២៣៤៦/២១ គ.វ.ក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ជេនេរ៉ល អេនធើប្រាយ ហ្គាម៉ិន (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ជេនេរ៉ល អេនធើប្រាយ ហ្គាម៉ិន (ខេមបូឌា) ឯ.ក (**GENERAL ENTERPRISES GARMENT (CAMBODIA) CO., LTD.**) តំណាងដោយលោកស្រី **CHUNG, WEN-LING** សញ្ជាតិចិន (តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ 360127759 ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ បង្កើតរោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងបាគេ ឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** **ISIC Rev.4 Code** |
|---|---|
| ១- សម្លៀកបំពាក់ (កាត់ដេរ) | ១៤១០ |
| ២- សម្លៀកបំពាក់ (ចាក់) | ១៤៣០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំ ស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ "**រោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ ដេនេរ៉ល អេនជើប្រាយ ហ្គាម៉ិន (ខេមបូឌា) ឯ.ក**"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

